ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤១...សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការ ដើម្បីស្រាវជ្រាវវត្ថុបុរាណ ដែលបានកប់ទុកក្នុងបរិវេណសារមន្ទីរវប្បធម៌ ខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ពិនិត្យសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការ ដើម្បីស្រាវជ្រាវវត្ថុបុរាណដែលបានកប់ទុកក្នុងបរិវេណសារមន្ទីរវប្បធមិ ខេត្តបាត់ដំបង តាំងពីឆ្នាំ ១៩៧០ រួមមានសមាសភាពដូចខាងក្រោម :

១- សម្តេចព្រះរាម **នរោត្តម បុប្ផាទេវី** រដ្ឋមន្ត្រីក្រសួងវប្បធមិ និងវិចិត្រសិល្បៈ ព្រះប្រធាន
២- ឯកឧត្តម **ខិម យ៉ិនសៀង** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី អនុប្រធាន
៣- ឯកឧត្តម **សេង លឹមនៅ** អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៤- ឯកឧត្តម **ហោ ឡុត** សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក
៥- ឯកឧត្តម **ឃឹម សារិទ្ធ** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក

www.pheakdeylaw.com

៦- លោក អ៊ុខ ទន ប្រធាននាយកដ្ឋានបិតិកភ័ណ្ឌវប្បធម៌ សមាជិក

៧- លោក ចុខ សុវត្ថិ មន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

៨- លោក OLIVIER de BERNON សមាជិកសាលាបារាំងចុងបូព៌ា ទីប្រឹក្សា

**ប្រការ ២ :** គណៈកម្មការស្រាវជ្រាវវត្ថុបុរាណ ដែលបានកប់ទុកក្នុងបរិវេណសារមន្ទីរវប្បធម៌ខេត្តបាត់ដំបង មានភារកិច្ច ដូចតទៅ :

-ធ្វើការទំនាក់ទំនង និងសហការជាមួយរដ្ឋអំណាចខេត្ត ដើម្បីរក្សាសុវត្ថិភាពក្នុងការជីកយកវត្ថុបុរាណ និងការដឹកជញ្ជូន

-ធ្វើការស្រាវជ្រាវជីកយកវត្ថុបុរាណ ចុះក្នុងបញ្ជីសារពើភ័ណ្ឌ ដោយដាក់លេខកូដ និងថតរូបផ្សព្វផ្សាយ ដើម្បីជៀសវាងការជួញដូរវត្ថុបុរាណទាំងនោះ ។

-ធ្វើការទំនាក់ទំនងជាមួយអ្នកជំនាញការសាលាបារាំងចុងបូព៌ា ដើម្បីកំណត់ពីអាយុកាល និងប្រភពនៃវត្ថុបុរាណទាំងនោះ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- កាលប្បវត្តិ-ឯកសារ ✓

www.pheakdeylaw.com